អធិប្បាយ! ប្រច័ណ្ឌរហូតដល់រឿងរ៉ាវ នៃអតីតកាលរបស់នាងទៀត។ ខ្ញុំចង់ស្រែកប្រាប់នាងថា : "អារ៉ាវ៉ាន់នេះជាមិត្តទ្រុស្តមិត្ត វាមានគោលបំណង មកចែចង់អូនឯងហ្នឹង. សូមអូនប្រយ័ត្ន កុំមានចិត្តទោរទន់ទៅរកវា។ ប៉ុន្តែនឹកសព្វៗទៅ បើសិនខ្ញុំប្រាប់ចិន្តាអោយនាងដឹងខ្លួនមុនដដែល តើធ្វើម្ដេចនឹងដឹងតម្លៃរបស់ប្រពន្ធខ្ញុំបាន?

បើប្រពន្ធយើងល្អមែន ទុកជាមានប្រុសៗ មកចែងចង់អោយវាមកចុះ ប្រពន្ធយើងកុំខូចនឹងគេទៅ វារួចគ្នាទៅហើយ!!

ខ្ញុំគិតឃើញវែងឆ្ងាយ! ខ្ញុំគិតឃើញសព្វគ្រប់! ប៉ុន្តែខ្ញុំនៅតែចម្លែងចិត្តដដែល! ធ្វើម្ដេចហ្ន៎! ដើម្បីរំលាយសេចក្តីមួហ្មងទាំងនេះ អោយអស់រលីងពីខ្លួន! ចិន្តាសម្លឹងមើលមុខខ្ញុំមួយសន្ទុះហើយសួរថា :

-បងអាល័យតែគិតទៅណាហ្នឹង?

-បងគិតមកអូនឯងហ្នឹងហ្ន៎!

ថាហើយខ្ញុំចាប់នាង ថើបជ្រមុជជ្រមុល ថើបដើម្បីបំភ្លេចទុក្ខ ថើបដើម្បីឱ្យរសាយការប្រច័ណ្ឌពីឱរា។ ខ្ញុំប្រព្រឹត្តស្នេហាជាមួយនាងភ្លាមមួយរំពេច! ម្ដងនេះខ្ញុំស្រឡាញ់នាង ខ្លាំងពេញបន្ទុក

ឡើងរញ្ជួយ ឡើងរង្គើ ឡើងស្រគៀវសាច់សព្វសារពាង្គកាយ!
*Je fais l'amour comme un condamné à mort*
ចិន្តាស្រែកថ្ងូរបរហឹមដោយសេចក្ដីសុខ!

ប៉ុន្តែដួងចិត្តខ្ញុំវិញ នៅតែតប់ប្រមល់ដដែល ។ ខ្ញុំស្រឡាញ់ចិន្តាខ្លាំងឡើង ខ្ញុំរិតតែប្រច័ណ្ឌនាងឡើង ។ នៅពេលដែលយើងប្រឱបគ្នាចាក់ស្រេះ រមួលរមួតពេញទីនៅពេលដែលព្យុះស្នេហាបោកបក់កាយយើង ផ្ដប់គ្នាយ៉ាងសែនញាប់ញ័រ ខ្ញុំនៅឆ្លៀតនិយាយប្រាប់នាងទាំងដង្ហោយដង្ហក់ ដូចមនុស្សចង់ដាច់ខ្យល់ :

-ចិន្តា អូនមាសបង! យើងស្រឡាញ់គ្នា របូតដល់ចាស់ណាអូនហ្នា! ជាតិក្រោយយើងជួបគ្នាទៀត!... អូនជាដង្ហើមអូនជាម្ចាស់ចិត្ត អូនជាម្ចាស់ស្នេហ៍របស់បង តាំងពីបងបានខ្លួនអូនមករួមរក្ស ចំនួនប្រាំខែមកហើយ បងមិនដែលក្រឡេកមើលនារីណាម្នាក់ទៀតឡើយ... សូម្បីបន្តិចបន្តួចក៏គ្មានដែរ...

ខ្ញុំនេះគឺមានគំនិតខូចតែម្ដង ។

ខ្ញុំនិយាយពាក្យចុងក្រោយប៉ុន្នានប្រាប់នាង គឺមានបំណងចង់ឱ្យនាងដឹងខ្លួនថា ប្ដីនាងមានចិត្តស្មោះត្រង់នឹងនាងខ្លាំងណាស់ សូម្បីតែកន្ទុយភ្នែក ក៏មិនដែលចោលទៅលើនារីណាឡើយ បើដូច្នេះ

ត្រូវនាងស្មោះត្រង់នឹងប្ដីនាងដែរ កុំក្រឡេកមើលបុរសណាទៀតជាដាច់ខាត ។

ខ្ញុំប្រព្រឹត្តស្នេហាជាមួយនាងម្ដងនេះ បានយូរអើយយូរ! ។ ពុំដឹងជាមានហេតុភេទចម្លែកយ៉ាងម្ដេច សាច់ចិន្ដាស្រាប់តែមានឱជារសរកថ្លែងពុំបាន ។ ខ្ញុំនឹកព្រួចទៅដល់សំដីអាសូផា "បើចង់អោយប្ដីស្រឡាញ់ ប្រពន្ធត្រូវយកសបាយ" ខ្ញុំគិតថាអានេះនិយាយខុសបន្ដិច បើនិយាយដូច្នេះវិញសមជាង "បើចង់អោយប្ដីស្រឡាញ់ ប្រពន្ធត្រូវធ្វើយ៉ាងម៉េចអោយប្ដីប្រច័ណ្ឌ"។ ព្រោះថាពេលនេះ ខ្ញុំកំពុងតែប្រច័ណ្ឌនឹងចិន្ដា ហើយរាងកាយចិន្ដា ដែលពេនពន់ដូចអន្ទង់ ស្រាប់តែមានរសជាតិឆ្ងាញ់អើយ សែនឆ្ងាញ់. ក្រអូបអើយសែនក្រអូប! ខ្ញុំឈ្លក់នឹងកម្លាំងស្នេហ៍លង់កប់រហូតដល់ឋានសួគ៌ហាសិបជាន់! ម្ដេចអញ្ចេះថ្ងៃនេះ កាយចិន្ដាក៏ឆ្ងាញ់ខ្លាំងម្ល៉េះ! ឆ្ងាញ់ណាស់! ឆ្ងាញ់ណាស់! ឆ្ងាញ់ដល់ទីបំផុតគ្មានឆ្ងាញ់ដល់ក៏រិតឈើផង ឆ្ងាញ់ផងរហូតដល់ខ្ញុំស្រែកថ្ងូរថា :

-អូយ! អូយ! អូយ! ចិន្ដាមាសបងអើយ!

~ ៤ ~

*កាលសូផា មិត្តខ្ញុំថ្លែងទុក្ខរបស់វាប្រាប់ខ្ញុំនៅក្នុងហាង ខ្ញុំខំអាណិតវាអស់សន្ទឹក ។ ខ្ញុំមិនបានទឹកគិតសោះថា វិបត្តិជីវិតខ្ញុំមានលំនាំប្រហាក់ប្រហែលនឹងរឿងវាដែរ ។ កាលនោះដោយដឹងថា អ្នកស្រីម៉ាលីស ប្រពន្ធវាជាស្រីហ្មចល្មាច ខ្ញុំខំសរសើរសំណាងខ្ញុំជាពន្លឹក នឹកស្មានច្រឡំថា ចិន្តាភរិយាខ្ញុំ ជាស្រីគ្រប់លក្ខណ៍ ។ តាមពិតទៅស្រីគ្រប់លក្ខណ៍ មានតែនៅក្នុងរឿងឥណ្ឋាតែប៉ុណ្ណោះ ។*

*ចាប់តាំងពីថ្ងៃអាទិត្យដែលអាវ៉ាវ៉ាន់ ទៅលេងផ្ទះខ្ញុំមក ខ្ញុំកើតទុក្ខមិនស្រណុកចិត្តគ្រប់ទិវារាត្រី ព្រោះនៅថ្ងៃបន្តបន្ទាប់មក អាទោះនៅតែឆ្សៀតមកវាយស្និទ្ធនឹងប្រពន្ធខ្ញុំ គ្មានលោះមួយវេលា ។ តាមខ្ញុំស្ទង់ចិត្តអាវ៉ាវ៉ាន់មើលទៅ អានេះចិត្តខូចអាក្រក់ មានពុតត្បុតដូចជាចង់បន្លំធ្វើលេងផង ធ្វើមែនផង ។ បើសិនជាវាលួចប្រពន្ធខ្ញុំមិនបានទេ វាធ្វើឫកវាហាក់ដូចជាធ្វើលេងទៅ ប៉ុន្តែបើសិនជាវាឱតបានវិញ វាពួយសម្លាប់ខ្ញុំគ្មានត្រាប្រណីឡើយ ។ មិនបានទេ អាខ្ជុតហ្នឹង តែប្រទះហើយវាស៊ីខ្ញុំក! ។*

ចំណែកអាកប្បកិរិយា ប្រពន្ធខ្ញុំវិញ ហាក់ដូចជាមិនប្រយ័ត្ន ហាក់ដូចជាមិនទាស់ចិត្ត នឹងរូបអាវ៉ាវ៉ាន់ ដែលមកលេងផ្ទះរាល់ថ្ងៃសោះ ។ កន្លែងនេះហើយដែលខ្ញុំក្តៅក្រហាយខ្លាំងណាស់ ។ មានម្តងខ្ញុំនឹកអន់ចិត្តនឹងចិន្តា ខ្លាំងហួសប្រមាណ ស្ទើរស្រក់ឈាមតាមភ្នែក ។ កាលនោះយើងជជែកគ្នា នៅក្នុងបន្ទប់និយាយចុះនិយាយឡើង ក៏ចូលរឿងអាវ៉ាវ៉ាន់!

-ឱ! អាវ៉ាវ៉ាន់ អើយអាវ៉ាវ៉ាន់! (សំដីរបស់ខ្ញុំ) អានេះរូបអាក្រក់ដូចពិទូរចរកា នៅក្នុងរឿងឥណ្ឌាអញ្ជើង ។ អាក្រក់នេះបានហៅអាក្រក់សែន ពោះកំពឹងកំប៉ោងពីរម៉ែត្រទៅមុខ មុខវាខ្មួតស៊ីឡើងខូងពីរតីឡូ សក់ក្បាលវាក្រញាំញ៉ក្រញ៉ិកដូចឫស្សីក្លិនវាស្អុយទ្រុតទៅក្នុងដីបីរយតីឡូ ។

-បងឯងក៏ចូលចិត្តបង្អាប់លោកវ៉ាវ៉ាន់ម្លេះ (ចម្លើយដ៏គួរខ្នាញ់របស់ចិន្តា) ធ្វើម្តេចធម្មជាតិមិនបានសាងរូបគាត់មកអោយបានល្អ ប៉ុន្តែចិត្តគាត់វិញល្អណាស់ ។

តាំងពីថ្ងៃនោះមក ខ្ញុំលែងទុកចិត្តចិន្តាតែម្តង ។ តើនាងជាប់ស្នេហ៍អីនឹងអាវ៉ាវ៉ាន់ បានជានិយាយការពារវាអញ្ចឹង? ខ្ញុំគិតវិលវល់ៗ យូរទៅចង់ឆ្កួតពាក់កណ្តាល ។ ថ្ងៃណាទៅខ្ញុំនិយាយរក

ចិន្តា ចុងមាត់ ចុងក ហាក់ដូចរូបនាងជាអ្នកក្រៅសុទ្ធចំពោះខ្ញុំ ។ ថ្ងៃណាទៅទៀត ខ្ញុំស្រឡាញ់នាងដូចជ្រូកពុល ស្រឡាញ់ញាប់ញ័រ តក្កហល ដូចពួកអ្នកដើរសមុទ្រ ដែលឃ្លាតចាកទីក្រុងរាប់ខែ ហើយដែលស្រេកឃ្លានកាយស្រីៗដូច្នោះ ។

ឱ! ខ្លួនខ្ញុំ មិនដឹងជាក្លាយទៅជាមនុស្សប្រភេទណាទេ! ម្តងឆ្កួត ម្តងជា! ម្តងដឹងខុសត្រូវ ម្តងផ្តេសផ្តាសអាវ៉ាសែ! ពេលណាខ្ញុំចេះគិតពិចារណា ខ្ញុំអន់ប្រច័ណ្ឌបន្តិច ខ្ញុំនឹកថា ឫកពារ ភិរិយាខ្ញុំគ្មានអ្វីគួរអោយមន្ទិលសង្ស័យសោះ គ្មានអ្វីជាភស្តុតាង ថាចិត្តនាងគួចស្នេហា ទៅលើអាវ៉ាវ៉ាន់ឡើយ ។ នាងគួរសមនឹង អាវ៉ាវ៉ាន់ គឺដូចចំពោះភ្ញៀវធម្មតាទេតើ ។ គឺខ្ញុំទេដែលចេះនឹក ឃើញព្រើលៗ តែម្នាក់ឯងទៅនិស្ស័យ ដូចជាមនុស្សវិកលចរិត ។ រឿងស្រីគេមិនមែនមិនអោយប្រច័ណ្ឌស្មោះនោះទេ ប៉ុន្តែមុននឹង ប្រច័ណ្ឌត្រូវយើងមើលសិនដែរ វាមានរឿងអ្វីគួរប្រច័ណ្ឌ? យើងគួរ ប្រច័ណ្ឌតែស្រីណាខូច ស្រីណាក្រឡិចក្រឡុច ស្រីដែលមានពុតត្បុត មាយាច្រើន ។ ចំណែកចិន្តា សេចក្តីស្មោះត្រង់នាង គឺឃើញលេច ឡើងជាក់នឹងភ្នែកទៅហើយ ចាំបាច់ខ្ញុំឆ្កើសកកាយដល់ណាទៀត ។

ប៉ុន្តែមានពេលខ្លះ ដែលមានព្រាយអពមង្គលចូលមក សណ្ឋិតក្នុងខួរក្បាលខ្ញុំ ខ្ញុំប្រែជានឹកឃើញដូច្នេះវិញ។ ធម្មតាបើគេប្រច័ណ្ឌស្រី គេប្រច័ណ្ឌតែស្រីណាល្អ តែស្រីណាមានតម្លៃប៉ុណ្ណោះទេ! តើយើងប្រច័ណ្ឌស្រីខូចក្រឡិចក្រឡុច បានការក្រម៉ស្រែងសម្រែងកង្កែបអី ធម្មជាតិវាតែប៉ុណ្ណឹងទៅហើយ។ ចំពោះមនុស្សប្រុសយើង បើមានតម្រង់ក្រខ្វក់អ្វីប្រឡាក់ដុំលាមក តើយើងឈឺចាប់បានការអ្វី យើងភ័យខ្លាច យើងខ្លាចតែវាមកប្រឡាក់ដល់មាស ដល់ពេជ្រ ដល់ត្បូងចរណៃរបស់យើងទេតើ។

ខ្ញុំខ្វល់ខ្វាយច្រើនហួសកំណត់ពេក ក៏លែងទុកចិត្តស្រីទាំងអស់នៅលើភពផែនដី។ ខ្ញុំនឹកទៅដល់រឿងមួយពាន់មួយយប់ដែលគេឃើញប្រពន្ធផិតប្តីរហូតគ្មានចប់ សូម្បីតែប្រពន្ធយក្សដែលវាដាក់នៅក្នុងប្រអប់តូចមួយ ក៏មានលាក់សហាយនៅក្នុងក្នុងសក់ដែរ។ ធម្មជាតិស្រីកើតមកគឺសម្រាប់តែស្រេកឃ្លានខាងផ្លូវកាមគុណ។ ស្រេកឃ្លាននោះ គឺហៅមហាស្រេកឃ្លានគឺរាប់រយដងលើសបុរស។ មើលចុះនៅក្នុងទំព័រប្រវត្តិសាស្ត្ររ៉ូមាំងព្រះនាងមេស្សាលីន (Messaline) ព្រះជាយាទី ៣ នៃព្រះចៅ

អធិរាជ រ៉ូម៉ាំង ក្លូដឺ (Claude)[១] បង្គាប់អោយប្រុសសហាយចូលមករួមដំណេកនឹងព្រះនាងរាប់មិនអស់។ ព្រះនាងឈ្លក់វង្វេងក្នុងតម្រេក. ពុំចេះឆ្អែតឆ្អន់នឹងតណ្ហា... បើប្រុសសហាយណាមិនមានសមត្ថភាពធ្វើអោយព្រះនាងរំភើបខាងផ្លូវកាមទេ នោះព្រះនាងទ្រង់បញ្ជាអោយគេពិឃាត នៅពេលព្រឹកស្អែកឡើង។ ព្រះនាងយកប្រុសមួយ ហើយមួយទៀត១១... គ្រាតែព្រះចៅក្លូដឺ ធ្វើគត់ព្រះនាងចោល ពេលព្រះនាងមានជន្មាយុ ៣៥ ឆ្នាំ គ្រាតែព្រះនាង មានឈ្មោះរន្ទឺល្បី ក្នុងទំព័រប្រវត្តិសាស្ត្រ។ ចំណែកព្រះនាង ក្លេអូប៉ាត្រេវិញ (Cléopâtre) ដែលជាម្ចាស់ក្សត្រីល្បីល្បាញជាងគេ ក្នុងប្រវត្តិសាស្ត្រ នៃប្រទេស អេហ្ស៊ីប (Egypte) ក៏មិនមែនមានប្រុសតិចតួចប៉ុន្មានដែរ ក្នុងជីវិតស្នេហារបស់ព្រះនាង។ ព្រះនាងកាថឺរីន ទី ២ នៅស្រុករុស្ស៊ី (Catherine II) ក៏ឆ្អើមណាស់ទៅទៀត ផ្នែកកាមតណ្ហា ឆ្អើមរហូតដល់មានគេនិយាយនៅក្នុង (Dictionnaire Larousse)។ នេះគ្រាន់តែតួអង្គដែលគេស្គាល់ផង ចុះនៅស្រីជំពូកនេះរាប់វាល់លានទៀតនោះ តើវាយ៉ាងណាទៅវិញ? មើលចុះ

---

[១] ឪពុករបស់ Britannicus

អ្នកប្រាជ្ញខ្មែរពីបុរាណ ក៏មានចារចែងអំពីតណ្ហាប្រុសកិរិតដូច្នេះដែរ នៅក្នុងប្រជុំរឿងព្រេងខ្មែរ។ ឧបមាដូចជារឿងមាយាស្រី ឬរឿងស្រីមាយាដកខ្វី។ ខ្ញុំនឹកឃើញរឿងទាំងនេះឡើង ស្រៀវញ័រញាក់រហូតដល់កន្ទុតអូង។ មិនបានទេ! កម្លាំងតម្រេកស្រីៗ ខ្លាំងជាងទឹកជ្រោះ ដែលហូរធ្លាក់ពីលើគិរីបព្វតាទៅទៀត... ប្រុសៗគ្រាន់តែជាស្ទឹង បឹងបួ, ជាអូរ... ជាទន្លេ, ចំណែកស្ត្រីវិញ ជាសមុទ្រធំធេងគ្មានអ្វីអាចធ្វើអោយស្កប់ស្កល់!!។ ស្រឡាញ់សហាយពេកទៅបន់អ្នកតាអោយប្តីស្លាប់! គ្រាន់តែសុំប្តីទៅដកខ្វី ក៏ឆ្លៀតផិតបានមួយពេលដែរ! មិនលេងកន្លែងណាស្រួលបួល លេងគ្នានៅគុម្ពខ្វីតែម្តង។ យី! អស្ចារ្យមែន! យប់ឡើងដែលគេឃើញលើភ្លៅប្តីហើយហ្នឹង នាងមាយាដកខ្វី នៅឆ្លៀតផិតបានមួយគ្រាទៀត! នាងបញ្ឆោតប្តីនាង របៀបឆ្លាតគួរអោយស្ញើចអោយផ្លុំប៉ុ ដោយបិទភ្នែកទាំងសងខាង។ ខ្ញុំចាំរហូតដក់ឃ្លាប្រយោគថែមទៀត កន្លែងស្រីមាយាបោកប្តីវា!

"-ពីរោះណាស់អ្នក! អ្នកផ្លុំប៉ុភ្នែកមើលរន្ធដែរឬទេ? បើអ្នកមិនមើលរន្ធ ធ្វើម្តេចនឹងចាប់បើកបិទត្រូវទំនុក?

ប្តីតបថា :

-ទេ មិនបាច់មើលរន្ធទេ ពីព្រោះដៃចាំស្ទាត់ហើយ ចំណាំរន្ធផង។

ប្រពន្ធតបថា ៖

-បើដូច្នេះ ខ្ញុំបិទភ្នែកអ្នកទាំងពីរមើល អ្នកនៅតែផ្លុំពីរោះដូចដែលឬទេ?

ប្តីតបថា ៖

-បិទចុះ ផ្លុំក៏នៅពីរោះដូចមុនដែរ

ប្រពន្ធយកដៃបិទភ្នែកប្តីខ្លួនទាំងពីររួចហើយ ក៏កន្ត្រាក់ជើងអោយសហាយនោះឃើញ។ ប្រុសសហាយ ឃើញស្រីសហាយបិទភ្នែកប្តីខ្លួនបាន ហើយកន្ត្រាក់ជើងអោយសញ្ញាដូច្នោះ ក៏ចូលទៅរួមសង្វាសនឹងនាងនោះទៅ។

លុះសហាយនោះថយចេញ ទើបប្រពន្ធលែងបិទភ្នែកប្តី។ ប្តីនោះ ក៏មិនអាចដឹងដល់កិច្ចកលនោះឡើយ។

ស្រីអើយនាងស្រី, ស្រស់ទៅដកខ្វី, ដកដួលទាំងខ្លួន, កាលដកលើកមុខ, តូចតន់លាក់ពួន, ដកក្រោយសំនួន, ផ្ទួនអោយប្តីស្តាប់, ប្តីនាងអ្នកផ្លុំ, នាងសុំធ្វើត្រាប់, បន្ទរអើងអាប់, ចប់បទអុំទូក"។

ពាក្យដ៏ពីរោះទាំងនេះ ខ្ញុំទន្ទេញយ៉ាងស្ទាត់ យ៉ាងខ្ជាប់ខ្ជួន នៅក្នុងដួងវិញ្ញាណ។ ខ្ញុំនឹកស្ញើចដល់អ្នកប្រាជ្ញបុរាណ ដែលយល់ធ្លុះយ៉ាងជ្រៅក្នុងចិត្តសាស្ត្រនៃមនុស្សស្ត្រី។

អារ៉ាវ៉ាន់នៅតែមកលេងផ្ទះខ្ញុំរៀងរាល់ថ្ងៃ ចំណែកខ្ញុំវិញកាន់តែឃ្លាតឆ្ងាយពីចិន្តា បន្តិចម្តងៗ ព្រោះកាលណាខ្ញុំនៅជិតនាង ខ្ញុំចេះតែនឹកគ្នាន់ក្នាញ់នឹងរូបរាងនាង កាន់តែខ្លាំងឡើងៗ ទុកតែប្រពន្ធខ្ញុំគ្មានប្រព្រឹត្តអ្វីខុសសោះ ក៏ខ្ញុំនៅតែងនឹកស្អាយរូបកាយនាងដែរ។ រូបសម្ផស្សនាងឆើតឆាយពន់ពេកណាស់ មិនគួរចិត្តថ្លើមនាងខ្មៅក្រខ្វក់ដូច្នេះសោះ។ លុះខ្ញុំជជីកសួរខ្លួនឯងថាខ្មៅក្រខ្វក់រឿងអ្វី ខ្ញុំមិនដឹងជាក្រខ្វក់រឿងអ្វីច្បាស់ផង។ ខ្ញុំចេះតែច្រៀងត្អូញត្អែរតែម្នាក់ឯង... ស្អាយអើយសែនស្អាយកាយចិន្តា... ទ្រូងអើយទ្រូងទ្រតស្ងួតខ្លោចផ្សា...

នៅទីបំផុតខ្ញុំក៏ដាច់ចិត្ត ដើរបាត់ៗពីផ្ទះ។ នៅក្រៅម៉ោងធ្វើការ ខ្ញុំទម្លាប់ខ្លួនផឹកស្រា ដើម្បីសម្លាប់ចិត្តកុំអោយនឹកនាដល់ចិន្តា ដល់ភរិយាម្ចាស់ស្នេហ៍របស់ខ្ញុំ!... ខ្ញុំមានបំណងមួយយ៉ាងមុតមាំ គឺឈប់ស្រឡាញ់នាង ព្រមទាំងឈប់ស្រឡាញ់ស្រីណាៗ ទាំងអស់លើផែនដី!...

## ~ ៥ ~

ខ្ញុំបំភ្លេចចិន្តាបានបន្តិចម្តងៗ ហើយ! ដោយមានពិសសុរាជួយបំពុលឈាមខ្ញុំខ្លះផង សម្រស់រាងកាយភរិយាខ្ញុំមានសភាពព្រិលទៅៗ រុះរោយជាលំដាប់ក្នុងដួងចិត្ត ។

មុនដំបូង ខ្ញុំមានសេចក្តីលំបាកក្នុងខ្លួនយ៉ាងខ្លាំង ក្នុងការរំលាយសេចក្តីស្នេហាខ្ញុំចោល ព្រោះខ្ញុំនៅរពួករូបនាងពេក ព្រោះអនុស្សាវរីយ៍របស់យើង កាលពីបានគ្នាគ្រាថ្មីៗ នៅមានឥទ្ធានុភាពមហិមា លើសតិរបស់ខ្ញុំ ។ ប៉ុន្តែលុះយូរថ្ងៃកន្លងមក ការប្រឹងប្រែងរបស់ខ្ញុំក៏បានសម្រេច ។ ជួនកាលខ្ញុំដើរពីផ្ទះបាត់បីបួនថ្ងៃទទេ ដោយគ្មានទឹកស្រណោះនាងបន្តិចបន្តួច ។

ពេលខ្ញុំត្រឡប់ចូលផ្ទះម្តងៗ ខ្ញុំឃើញទឹកមុខចិន្តាស្លូតស្រពោន ប៉ុន្តែខ្ញុំមិនដែលខ្វល់ខ្វាយ ឬព្រួយបន្តិចឡើយ មានរឹតតែក្តាញ់ទៀតផង ។ ខ្ញុំទន្ទេញជាប់នឹងមាត់ថា "រូបល្អពេក មិនគួរឡើយចិត្តក្រខ្វក់ ស្អុយរលួយដូច្នេះសោះ" ។ ចិន្តាចេះតែសម្លឹងមើលមុខខ្ញុំ ធ្វើអោយខ្ញុំនឹកឆ្ងល់ជាពន្លឹក តើនៅក្រសែភ្នែកនាងមានអ្វីខ្លះ? តើនាងនៅនឹកអាក់អន់ ឬយ៉ាងម្តេច? តើនាងយល់ឆ្លុះដល់ក្នុងចិត្តខ្ញុំ ដែលកំពុងកាត់ផ្តាច់ពីនាងឬទេ?

ពិបាកយល់ណាស់ចិត្តស្រី១!

ប៉ុន្តែទុកជាយ៉ាងណាក៏ដោយ ឥឡូវនេះខ្ញុំមិនដែលខំត្រិះរិះអោយខាតពេលសោះអំពីរូបភរិយាខ្ញុំ ។ ខ្ញុំឧបមាទុកនាងដូចជារូបថ្មចម្លាក់មួយ ឬដូចជាគល់ឈើ ឬដូចជាមនុស្សស្លាប់ដូច្នោះចំពោះខ្ញុំ ។ ខ្ញុំចូលផ្ទះតែមួយភ្លែត១ ដូចអំពិលអំពែក ។ ពេលទំនេរពេលក្រៅម៉ោងធ្វើការ ខ្ញុំច្រើនតែកំសាន្តលេងប៉ោឡែនៅផ្សារផ្សេងៗនៅក្នុងតៀមស្រា ឬនៅក្នុងបនសំផឹង ។

នៅពេលខ្លះខ្ញុំនឹកអរព្រួច អរនឹងមានសេរីភាពដើរផ្សងព្រេងបានតាមក្បាលចិត្ត អរដោយបានរួចខ្លួនពីភាពកញ្ចះនៃតណ្ហា អរដោយបានបំភ្លេចចោលចិន្តា ដែលជាភរិយាម្ចាស់ចិត្តខ្ញុំ ។ ចំណែកអារ៉ាវ៉ាន់តាមខ្ញុំដឹង អានោះភ្លេចប្រពន្ធកូន ភ្លេចផ្ទះសម្បែងគ្មានសល់ វាទៅលេងផ្ទះខ្ញុំសឹងតែ permanent [(១)] ទៅហើយ ។ ប៉ុន្តែការទាក់ទង ចងស្ពានមេត្រីរវាងរូបវា និងចិន្តាពុំដឹងជាឡើងដល់កម្រិតណាទេ ខ្ញុំរកស្មានមិនទាន់បាន ។ ចំណែកខ្ញុំ១ មិនដែលអោយជួបមុខអារ៉ាវ៉ាន់ទេ ព្រោះខ្ញុំនឹកខ្ពាសវារបួត

---

(១) អចិន្ត្រៃយ៍

ដល់ក្នុងសួត ដល់ក្នុងប្រមាត់ ខ្ញុំគ្រាន់តែគិតថ្ងៃណាមួយ ខ្ញុំសរសេរសំបុត្រទៅប្រាប់វា ឱ្យវាយកចិន្តាធ្វើភរិយាចុងតែម្តងទៅចុះ ។

ខ្ញុំប្រុងប្រៀបលែងចិន្តាចោលមែនទែនហើយ! ចំណែកបញ្ហាម្តាយខ្ញុំ ដែលរស់នៅជាមួយគ្នានោះ មិនជាពិបាកដោះស្រាយអ្វីទេ ។ តែគ្មាននរណារវីរវល់ជាមួយនឹងគាត់ៗ មុខជាត្រឡប់ទៅនៅស្រុកកំណើតរបស់គាត់វិញហើយគឺ "កោះលួង" ។ នៅពេលដែលខ្ញុំប្រាកដក្នុងចិត្តថា ខ្ញុំត្រូវបោះបង់ចោលចិន្តា ខ្លួនខ្ញុំក៏មានភាពស្រាលស្ញើកដូចសំឡី! ខ្លួនខ្ញុំហាក់ដូចជាអណ្តែតត្រសែតទៅក្នុងអាកាសវេហាស៍! ។

ល្ងាចថ្ងៃមួយ ជាល្ងាចថ្ងៃសៅរ៍ ថៅកែខ្ញុំបានប្រាប់ខ្ញុំអោយរៀបចំប្រុងប្រៀបខ្លួន ទៅខែត្រស្ទឹងត្រែង ជាមួយនឹងគាត់នៅពេលព្រឹកស្អែកឡើង "ម៉ោងបួនភ្លឺ" ។ គាត់បញ្ជាអោយខ្ញុំរៀបចំវ៉ាលីសជាស្រេច ហើយមកទទួលទានដំណេកនៅផ្ទះគាត់តែម្តង ។ ខ្ញុំពួដូច្នោះភ្លាម ក្នុងចិត្តសប្បាយកញ្ជ្រោលតែខាងក្រៅ គ្មានអោយនរណាដឹងឡើយ ។ តែប៉ុណ្ណោះ ខ្ញុំនឹងបានឃ្លាតចិន្តាហើយ ។ "ឃ្លាតកាយណាយចិត្ត!"... នេះគឺជាសុភាសិតបូរាណមួយដែលមានតម្លៃលើសលែង... ។

មកដល់ផ្ទះភ្លាម ខ្ញុំរៀបអីវ៉ាន់ប្រដាប់ប្រដា ដែលបម្រុង យកទៅធ្វើដំណើរ ដោយគ្មានរវីរវល់នរណាទាំងអស់។ ប្រពន្ធខ្ញុំ មកអង្គុយសសៀរក្បែរខ្ញុំ ហើយសួរខ្ញុំថា :

-បងរៀបអីវ៉ាន់ទៅណាហ្នឹង?

-បងទៅស្ទឹងត្រែងជាមួយថៅកែ មិនដឹងជាយូរ ឬឆាប់ទេ! អូនចាំផ្ទះផងណា? (ខ្ញុំធ្វើជានិយាយទន់ភ្លន់)។

-ចុះយប់នេះ បងមកគេងផ្ទះឬទេ?

-បងឥតបានមកទេអូន ព្រោះថៅកែអោយបងនៅគេង ផ្ទះគាត់!

ខ្ញុំឃើញមុខប្រពន្ធខ្ញុំ១ ស្រាប់តែនឹកក្តៅក្រហាយយ៉ាងខ្លាំង ស្ទើរតែស្ទុះទៅទះកំផ្លៀង. ប៉ុន្តែខ្ញុំខំសម្រួលចិត្ត ព្រោះយ៉ាងម៉េច ក៏យើងត្រូវបែកគ្នាដែរ ក្នុងពេលបន្តិចទៀត។

ចិន្តាមានទឹកមុខក្រៀមក្រំជាខ្លាំង

-បង! អូនសូមចិត្តចុះ យប់នេះសូមបងមកគេងផ្ទះណា បងណា សូមបងអាណិតចិត្តអូនផង យប់នេះមកគេងផ្ទះវិញ កុំខាន... កុំខានអោយសោះ។

នាងអង្វរខ្ញុំដោយហូរហៀរទឹកភ្នែកមកសស្រាក់ តែខ្ញុំមិនខ្វីទន់ចិត្ត ។ នាងបន្ថែមទៀតថា...

-យប់ណាទៀតមិនអីទេបង, ប៉ុន្តែយប់នេះ ត្រូវបងមកគេងនឹងអូនជាដាច់ខាត ។

ខ្ញុំតបទៅនាងវិញរបៀបព្រងើយ :

-បងត្រឡប់មកវិញមិនបានទេ! តែខំថៅកែខឹងបងងាប់ហើយ!

ថាហើយ ខ្ញុំយួរវ៉ាលិសចេញទៅយ៉ាងពើយើ, យ៉ាងសង្ហាអស់ពីចិត្ត ។ មកដល់មាត់ជណ្តើរ ខ្ញុំឮចិន្តាស្រែកហៅខ្ញុំថា "បង!" ។ ខ្ញុំងាកទៅវិញ ឃើញទឹកមុខនាងស្លាំងស្លេក រកឈាមមួយតំណក់គ្មាន ។

បន្តិចក្រោយមក ខ្ញុំជិះរ៉ឺម៉កទៅផ្សារកំពង់ចាម..............

គឺជាវេលាយប់, ខ្ញុំក្រឡេកមើលនាឡិកា ឃើញទ្រនិចចង្អុលម៉ោង ១១ ទៅហើយ ។ ខ្ញុំលើកកែវស្រាឡើងអកបង្ហើយ បម្រុងរៀបចំចូលដំណេក ។

ថៅកែខ្ញុំ បានអោយគេរៀបចំបន្ទប់មួយយ៉ាងតូចស្អាតសម្រាប់ខ្ញុំ ។ ខ្ញុំងុយគេងបន្តិចទៅហើយ ប៉ុន្តែខ្ញុំមិនទាន់លោតទៅ

ទ្រាលលើពូកនៅឡើយទេ ខ្ញុំនៅទម្រេតលើកៅអីបង្អែកបន្តិចសិន ដើម្បីគិតគូរអំពីរឿងជីវិតរបស់ខ្ញុំ ។

ខ្ញុំនឹកថាតែប៉ុណ្ណេះ ចិន្តា និងខ្ញុំត្រូវដាច់គ្នាហើយ ព្រោះខ្ញុំទៅស្ទឹងត្រែងម្តងនេះ ខ្ញុំទៅបង្ហូត ខ្ញុំបង្ហូសទៅដល់ស្រុកលាវ ហើយឆ្លងកាត់ទៅក្នុងស្រុកយួន រួចទៅស្រុកចិនទៀត ខ្ញុំដើរផ្សងព្រេងលែងត្រឡប់តែម្តង ។ គិតដូច្នោះហើយ ខ្ញុំដើរចេញទៅក្រៅបន្ទប់ ហួចបទមួយយ៉ាងស្រណោះ ខ្ញុំច្រត់ដៃលើបង្កាន់ដៃរានហាល ហើយសម្លឹងមើលទៅដី ។ ខ្ញុំលាន់មាត់ថា "យី ផ្ទះនេះខ្ពស់ណាស់ហ្ន៎ មើលតែជិះកបាល់ហោះតែម្តង!"

រំពេចនោះ ខ្ញុំវិលមុខស្លុង ហើយមានចិត្តចង្រៃមួយជម្រុលខ្ញុំអោយលោតទៅដី ។ បើសិនជាខ្ញុំលោតទៅ ក្បាលខ្ញុំនឹងទង្គិចឥដ្ឋស៊ីម៉ងត៍ បែកសំប៉ែតចេញខួរមិនខាន ។ យី! សប្បាយអស្ចារ្យរ៉ុយៗ ហើយវ៉ើយ ។

ខ្ញុំហៀបតែលោតវ៉ឺទៅហើយ ស្រាប់តែមានស្មារតី ទប់ខ្លួនទាន់មកវិញ ដៃខ្ញុំស្រវាចាប់ចង្រឹងបង្កាន់ដៃគ្មានរបេះ ។ បន្តិចមកខ្ញុំដើររបៀបអស់កម្លាំងល្វើយចូលមកបន្ទប់ ហាក់ដូចជានឹកស្តាយដោយមិនបានធ្វើឃាតកម្មចំពោះខ្លួនឯង ។

ពេលនោះហើយ ទើបខ្ញុំភ្ញាក់ដឹងខ្លួនថា ខ្ញុំគ្មានបានឈប់ស្រឡាញ់ចិន្តា មួយនាទីសោះឡើយ ប៉ុន្តែខ្ញុំស្រឡាញ់នាងថ្ងៃឡើងទេតើ ស្រឡាញ់រហូតដល់ចង់រត់ចោលស្រុក ស្រឡាញ់រហូតដល់ចង់សម្លាប់ខ្លួនឯង។ រាត្រីនោះជារាត្រីត្រជាក់ មានសន្សើមធ្លាក់មកជោកជាំផែនដី ប៉ុន្តែក្នុងខ្លួនខ្ញុំវិញទៅជាក្តៅស្ទុះស្ទាប់មានញើសធំៗ ប៉ុនគ្រាប់ពោត ហូរស្រោចស្រប់លើសារពាង្គកាយ។ ខ្ញុំដើរចុះទៅដីយ៉ាងប្រញាប់។

យប់នេះ មានបរិយាកាសត្រជះត្រជង់ល្អណាស់ លោកអើយ កាយខ្ញុំស្រាប់តែស្រេកឃ្លានកាយចិន្តាខ្លាំងពន់ប្រមាណ។ ខ្យល់រំភើយ, ព្រះច័ន្ទពេញបូណ៌មី, រុក្ខជាតិស្រស់ញញឹមដោយតំណក់សន្សើម ទិដ្ឋភាពទាំងនេះ ធ្វើអោយតណ្ហាខ្ញុំ ឆេះរោលរាលពេញទំហឹង! ខ្ញុំខានរួមរក្សរួមស្នេហ៍ជាមួយចិន្តា អស់ដប់ប្រាំថ្ងៃមកហើយ។ ឥឡូវខ្ញុំទ្រាំទៅទៀតមិនបានទេ ខ្ញុំរត់ទៅរកប្រពន្ធខ្ញុំសិនហើយ។ ចិន្តាអូនអើយអត់ទោសអោយបងផងហ្នាំ!។

បើប្រសិនជានៅពេលព្រឹកព្រហាម ឬនៅម៉ោងដប់ថ្ងៃត្រង់ប្រហែលជាតម្រេកខ្ញុំ គ្មានសន្ទុះខ្លាំងណាស់ណាទេមើលទៅ។ ប៉ុន្តែនៅពេលនេះ គឺពេលពាក់កណ្តាលអធ្រាត្រ ពេលនេះហើយ

ដែលប្រុសៗយើង "ចង់ស្រី" ខ្លាំងណាស់ ចង់មហាចង់ ចង់ឡើងរមួលខ្លួន វាវមោស់ឃ្លានរកអ្វីប្រៀបពុំបាន។ ស្នេហា គឺដុះឡើងដោយសារបរិយាកាសតែម្តង មានពេលណាទៅយើងខ្ទើមរអើម វាចង់កួតពេលណាទៅទៀត ដោយអំណាចកាមគុណ យើងប្រែជាសុខចិត្តសម្លាប់គេឯង ដើម្បីឱ្យបានឱបកាយស្រីមួយភ្លែត...។

ចំណែកខ្ញុំវិញពេលនេះ បើត្រឹមតែរកស្រីទេ គឺខ្ញុំបំពេញបំណងខ្លួនឯងបានភ្លាម។ ប៉ុន្តែ ខ្ញុំឃ្លាន គឺឃ្លានប្រពន្ធឯងជាពិសេសតែម្តង ឃ្លានច្រមុះនាង ឃ្លានបបូរមាត់នាង ឃ្លានដើមទ្រូងនាង ឃ្លានត្រគាកនាង ឃ្លានកំភួនជើងនាង អ្វីៗរបស់នាងក៏ឃ្លានដែរ។

ឃើញទេ? សមមុខខ្ញុំហើយ! គ្រាន់តែខ្ញុំចង់រត់ចោលនាង ជីវិតខ្ញុំអស់ន័យភ្លាមមួយរំពេច ខ្ញុំចង់លោតដាំដូង ពីលើឡៅផ្ទះថៅកែខ្ញុំមក ដែលមានកំពស់ជាងម្ភៃម៉ែត្រពីដី។ តាមពិតទៅខ្ញុំដឹងស្រេចទៅហើយថា វត្ថុអ្វីក៏ដោយ ដែលគេនិយមថា មានតម្លៃនោះ គឺគ្មានតម្លៃសោះក្នុងវដ្តសង្សារ។ ព្រោះជីវិតឥតន័យ... ជីវិតឥតន័យ! បើជីវិតឥតន័យទៅហើយ តើរបស់អ្វី ដែលមានន័យទៅវិញនោះ។ គ្មានទេ! ជីវិតជាថ្នកល្ខោន ជីវិត គឺជាល្បែង ដូចជាល្បែងបៀកាតេ ឬល្បែងចាក់អាប៉ោង ខ្លាឃ្លោកដូច្នោះ។

ចំពោះចិន្តាវិញ ក៏ខ្ញុំដឹងដែរ នាងមិនមែនជាន័យអ្វីពិត ប្រាកដចំពោះខ្ញុំឡើយ! ប៉ុន្តែបើខ្ញុំបោះបង់ចោលនាង គឺហាក់ដូចជា ខ្ញុំធីបអាត់ ធីបអាតា ធីបកូនក្រមុំចោលដូច្នោះ តើបានអ្វីនឹង ចាក់ទៀត? បើខ្ញុំធីបនាងចោល តើខ្ញុំបានអ្វីលេងជាល្បែង? ព្រោះជីវិតជាល្បែងសុទ្ធសាធ បើអត់អ្វីលេងទេ បើអត់ចិន្តាទេ... ធុន់ណាស់!! ឥតតម្លៃបញ្ឆោត... ខ្ញុំទ្រាំទ្រជីវិតលែងបាន។ ព្រោះ ខ្ញុំមិនដឹងទៅណាទៀត??... ទៅណាទៀតក៏ដូចជាឥតទៅណា... ចិត្តវាមិនស្រណុកទៅហើយ ទៅសាំងកាប៉ូ ក៏ដូចជានៅកំពង់ចាម។

ខ្ញុំដើរមកដល់ផ្លូវបែកចូលវត្តអង្គរ ខ្ញុំក្រឡេកមើលនាឡិកា ឃើញម៉ោង ១២ កន្លះ។ ពេលនោះខ្ញុំភ្ញាក់ខ្លួនព្រើត ដោយឃើញ ស្រីម្នាក់រាងល្អតល្វៃ សក់រំសាយក្រោមរស្មីព្រះច័ន្ទ ដើរចូលតាម ផ្លូវលំ ដែលនាំទៅឃុំអំពិលវត្តអង្គរ។

ស្រីនោះមិនបានឃើញខ្ញុំទេ. នាងដើរហាក់ដូចកំពុងយល់ សប្តិមមើមមាយដូច្នោះ។ ខ្ញុំសម្លឹងមើលទៅនាង ឃើញនាង មានភិនភាគ ដូចចិន្តាភរិយាខ្ញុំអីម្ល៉េះទេ។ ខ្ញុំក៏ដើរចូលតាមនាង ភ្លាមមួយរំពេច តាមរហូតដល់វត្តអង្គរ ហើយហួសទៅក្រោយ សំណាកបុរាណនេះទៀត រហូតដល់វាលស្រែ។ ទទួលពេលនោះ ស្រីចម្លែកលើកដៃជ្រងសក់នាងឡើង ហើយងាកទៅចំហៀង

ទើបខ្ញុំស្គាល់ប្រាកដថា ស្រីនេះជាប្រពន្ធខ្ញុំ គឺចិន្តា។ ខ្ញុំស្គាល់ខ្ទង់ច្រមុះនាងច្បាស់ណាស់ ហើយកាយវិការនេះ គឺជាកាយវិការនាងទាំងស្រុង ។

ខ្ញុំមានចិត្តអរព្រួច អរដូចបានត្រូវឆ្នោតដប់ម៉ឺន អរដោយបានជួបប្រពន្ធខ្ញុំក្នុងពេលនេះ ។ ប៉ុន្តែខ្ញុំមកនឹកឆ្ងល់បន្តិច តើនាងចេញពីផ្ទះធ្វើអ្វីថ្មើរណេះ តើនាងមានអាការៈក្តៅស្ពុះស្ពាប់ក្នុងខ្លួនឬមួយក៏ចង់ធ្វើអត្តឃាតកម្ម ដូចជារូបខ្ញុំអម្បាញ់មិញដែរ? ។ ខ្ញុំនឹកឃើញដូច្នោះភ័យជាខ្លាំង ហើយមានចិត្តចង់ស្រែកបង្អូកហៅនាង ។ ប៉ុន្តែខ្ញុំទប់មាត់ជាប់នៅស្ងៀមវិញ ដោយខ្ញុំចង់រត់ស្ទុះទៅឱបនាងពីក្រោយ ហើយថើបនាង ហើយលួងប្រលោមនាង ហើយប្រព្រឹត្តកាមគុណជាមួយនាង កណ្តាលវាលស្រែតែម្តង ។

ខ្ញុំបង្ហំជើងតាមនាង នៅប្រហែលដប់ម៉ែត្រប៉ុណ្ណោះ នឹងទាន់នាងហើយ ស្រាប់តែខ្ញុំឃើញនាងឡើងលើរានមួយយ៉ាងធំ ដែលមានគេផ្ទុកដោយពំនូកចំបើង ។ ជាបន្ទាន់នោះមានស្រមោលមនុស្សប្រុសម្នាក់ ឱនឈោងជួយទាញខ្លួននាងឱ្យឡើងលើរាន ។ ខ្ញុំឃើញដូច្នោះ ក៏ទុចង៉ក់ថយក្រោយមកវិញពីរជំហាន ហើយពួនអែបនឹងដើមឈើមួយ ដើម្បីពិនិត្យមើលស្ថានការណ៍ ។ អាប្រុសដោយខំទប់នាងចិន្តាមិនអោយដួល វាក៏បែរខ្លួនមកចំព្រះច័ន្ទពេលនោះទើបខ្ញុំស្គាល់វាជាក់ : គឺអាវ៉ាវ៉ាន់! មិត្តទ្រុស្តមិត្ត!

ខ្ញុំស្ងាត់! ខ្ញុំស្លន់ជាខ្លាំង មិនដឹងជាធ្វើយ៉ាងណា! ចង់ទន់ក្បាលផ្អួងដូចគោដឹកសៀង. ភាពស្រឡាំងកាំងនេះ លាយឡំនឹងការចុកចាប់ផង បណ្តាលអោយទ្រូងខ្ញុំតឹងមហាតឹង អោយដង្ហើមខ្ញុំថប់ដូចជាមនុស្សចង់ផុតខ្យល់។ ខ្ញុំគួរតែកុំក្រឡេកមើលទិដ្ឋភាពអពមង្គលនេះ ដើម្បីគោរពកិត្តិយសខ្លួនឯងផង។ ប៉ុន្តែមិនដូច្នោះទេ ខ្ញុំខំបើកភ្នែកធំៗ មើលដោយស្រេកឃ្លាន ហាក់ដូចជាមហាចោរដែលក្រឡេកឃើញ ឃ្លាំងមាសចំហចោលដូច្នោះ។

រានចំបើងនេះមានលំនាំដូចជាឆាកល្ខោន បំភ្លឺដោយគោមព្រះច័ន្ទ។ អាវ៉ាវ៉ាន់ចាប់ដៃចិន្តាទាំងពីរ ហើយទាញនាងមកដើម្បីក្រសោប។ នាងខំបម្រះឡើងរមួលខ្លួន ខំថយក្រោយកុំអោយអាវ៉ាវ៉ាន់ឱបថើបបាន។ ដោយអំណាចភ្លើងព្រះច័ន្ទ ខ្ញុំបានសង្កេតឃើញទឹកមុខនាងច្បាស់។ ខ្ញុំឃើញបបូរមាត់នាងពេបឡើងខូច. ខ្ពើមក៏ខ្ពើម. ខ្ពើមនឹងអារូបអាក្រក់របស់អាវ៉ាវ៉ាន់. ប៉ុន្តែចង់ក៏ចង់. គឺចង់ភ្លក្សរសជាតិសាកល្បងល្បែងស្នេហាជាមួយនឹងរូបវា។ ចិន្តានាងត្រញែងខ្លួន ដោយតម្រេកផង និងដោយរអើមផង ចង់ទៅមុខបន្តិច ចង់មកក្រោយបន្តិច កាយវិការនាងមានភាពដូចកិន្នររេរាំ។

បន្ទាប់មក ពុំដឹងជាយ៉ាងម៉េច ខ្ញុំមើលមិនទាន់ស្រាប់តែចិន្តាបែរខ្នងអោយអារ៉ាវ៉ាន់។ អានោះបានឱកាសក៏កេវត្រគាកនាងមួយរំពេច ចិន្តាខំបម្រះ នាងក្រលៀសក្រលីតខ្លួនឡើងវិលទីបំផុតចង្កេះនាង ក៏ត្រូវផ្ទប់ផ្ទាប់នឹងចង្កេះអារ៉ាវ៉ាន់. ត្រគាកសង្កៀតនឹងត្រគាក។ ចិន្តាប្រឹងជំអើតជើងឡើង។ អ្នកទាំងពីរខំជំនះទៅ ជំនះមកមិនចេះចប់ មើលតែគេរាំទ្វីស។

គេលេងស្នៀតនេះបានបន្តិច ប្តូរទីកន្លែងវិញ. ម្តងនេះអារ៉ាវ៉ាន់អាចឱបនាងចំពីមុខតែម្តង។ ប្រហែលជានាងរសើបក្បាលពោះហើយមិនដឹង (ព្រោះក្បាលពោះអារ៉ាវ៉ាន់ប៉ោង ទល់នឹងក្បាលពោះនាង) នាងក៏រុញច្រានដើមទ្រូងវាចេញ។ នាងភ្ញើយកនាងទៅក្រោយ ដើម្បីកុំអោយវាថើបបាន។ ដោយកាយវិការនេះនាងភ្លាត់ជើងដួលផ្ងារតែម្តង។ អារ៉ាវ៉ាន់ក៏រអិលខ្លួនសង្កត់ពីលើនាងជាប់ មុខទល់នឹងមុខ នៅលើពំនូកចំបើងដ៏ក្រាស់។

ខ្ញុំញ័ររញ្ជាក់ឈឺចាប់កន្ត្រាក់ពេកក្រៃ ដូចជាអាសារឡូ ត្រូវគ្រាប់កាំភ្លើង ព្រោះឃើញចិន្តារៀបចំនឹងផិតខ្ញុំ មែនទែនហើយ! ពេលនេះគឺកិរិយាខ្ញុំតែម្តង ដែលបើកស្មៀតអោយគេ។ កាលដែលអារ៉ាវ៉ាន់ដួលជិះពីលើនាង នាងឆ្លៀតពើងដើមទ្រូងនាងអោយវា

ពិត ហើយហុចមុខនាងអោយវាថើប ។ ទីបំផុតដោយដៃទាំងពីរនាងសើយលាត់សំពត់នាងឡើងសម្រាប់វា ។ ពេលនោះក្បាលពោះនាងញ័រពើត១ ភ្លឺរលោងដូចដូងមាសដោយពន្លឺព្រះខែ ។ ចំណែកភ្លៅដ៏ម៉ដ្ឋខៃរបស់នាង នៅតែរាំទ្វីសជានិច្ច រាំយ៉ាងរហ័នទទ្រើក! នាងរុញក្បាលពោះនាងផ្ទប់នឹងក្បាលពោះអារ៉ាវ៉ាន់ ហើយអ្នកទាំងពីរក៏ប្រឱបគ្នា ប្រកៀវប្រគងរឃើញរឃុង ទឹងណាត់ទឹងណែង រមៀលធ្លាក់កប់បាត់ទៅក្នុងរណ្តៅចំបើងទៅ ។

ខ្ញុំស្តាយអើយសែនស្តាយ ស្តាយដោយគូរាំទាំងពីរលិបខ្លួនបាត់ទៅក្នុងទីងងឹត ។ នៅពេលដែលគូនេះកំពុងតែប្រកាច់លេងស្មៀតញ៉ើកជាមួយគ្នា ខ្ញុំងណោះក៏ប្រកាច់តាមខ្លួនខ្ញុំដែរ ។ ខ្ញុំសង្កៀតជើងធ្មេញ លោតផង ទាត់ដើមឈើផង បោកសក់ផង ខ្ទេះច្រមុះខ្ទេះភ្នែក ស្ទាបដើមទ្រូង ច្របាច់ក្តៅរីភេទ ហើយបំបះខ្លួនដូចកញ្ចាញ់ចេកអញ្ចើង ។ ខ្ញុំឈឺចុកចាប់ណាស់ម្ចាស់ម៉ែអើយ ។ ពេលនេះខ្ញុំសូមស្បថចុះ ខ្ញុំស្រឡាញ់ចិន្តាក្រៃណានឹងស្រឡាញ់ បើនាងប្រើខ្ញុំអោយទៅលួច គ្រាប់បែកបរមាណូ នៅស្រុករុស្ស៊ី ក៏ខ្ញុំសុខចិត្តទៅដែរ អោយខ្ញុំសម្លាប់ខ្លួន ក៏ខ្ញុំសម្លាប់ទៀត ។ "បងស្រឡាញ់អូនណាស់ អូនអើយ អូនជាម្ចាស់ស្នេហ៍" ។ ខ្ញុំចង់ស្ទុះទៅទាញ

ខ្លួនអារ៉ាវ៉ាន់ចេញពីខ្លួននាង ដើម្បីខ្ញុំចូលប្រឡែងប្រឡូកនាងម្តង ។ ពេលនោះ ខ្ញុំនឹកសរសើរដល់គំនិតរបស់អាស្ងួផាជាខ្លាំង ។ កាលនៅក្នុងហាង អានេះបានប្រាប់ខ្ញុំថា "ប្រពន្ធយើង បើគេមានសហាយ យើងនឹងស្រឡាញ់គេលើសមុនដប់ដង" ។ ឱ! អានេះ បានចំជាប៉ិនប្រសប់ គ្រាន់បើមែនខាងយល់បញ្ហាវិបត្តិផ្លូវចិត្ត នៃប្រុសៗពេលប្រពន្ធផិត ។ ប៉ុន្តែបើគិតអោយសព្វទៅ ប្រពន្ធវាផិតមុនខ្ញុំបានជាវាដឹងដូច្នេះ ។

ខ្ញុំខំរត់ចេញពីទីនោះយ៉ាងប្រញាប់ ព្រោះបើខ្ញុំនៅយូរ ខ្ញុំច្បាស់ជាសម្លាប់អារ៉ាវ៉ាន់ចោលមិនខាន ។ មិនមែនសម្លាប់ដោយក្តៅក្រហាយនឹងវានោះទេ ប៉ុន្តែសម្លាប់ដោយចង់ដណ្តើមរួមតម្រេកជាមួយចិន្តា ។

ខ្ញុំដើរបណ្តើរ គិតបណ្តើរ. ខ្ញុំយល់ច្បាស់ដល់ចិត្តភរិយាខ្ញុំភ្លាមក្នុងរំពេចនោះ ។ ខ្ញុំដឹងថាបើខ្ញុំនៅផ្ទះវិញ នាងប្រាកដជាគ្មានផិតខ្ញុំទេ ។ តាមខ្ញុំស្មានមើលទៅ អារ៉ាវ៉ាន់បានណាត់នាងមកជួបគ្នានៅយប់នេះ ពេលពាក់កណ្តាលអធ្រាត្រ ។ ដូច្នេះហើយបានជាកាលពីថ្ងៃ នាងមានទឹកមុខភ័យរន្ធត់ ហើយអង្វរអោយខ្ញុំនៅគេងផ្ទះ នាងមិនមែនខ្លាចអារ៉ាវ៉ាន់ទេ ប៉ុន្តែនាងភ័យស្លុតខ្លាចទប់

ខ្លួននាងមិនជាប់ទេតើ! ឥឡូវនេះ. ដោយខ្ញុំមិនព្រមធ្វើតាមសំដីនាង អាវ៉ាវ៉ាន់ក៏ឆក់ខាបយកខ្លួននាងបានបណ្តោយទៅ! ធម្មតាមនុស្ស រូបអាក្រក់ដូចអាវ៉ាវ៉ាន់ តែងតែមានស្នេហ៍ចម្លែក វាធ្វើអោយស្រី ខ្លាចវាផង វាធ្វើអោយស្រីចង់វាផង ឧបមាដូចជាសត្វពស់វែក ស្រវែង ដែលមានស្រការខ្មៅរលើប ហើយដែលធ្វើអោយយើង រអាផង ចង់លូកដៃទៅស្ទាបលេងផងដូច្នោះ ។ គ្រាន់តែឃើញ កាយវិការចិន្តា អម្បាញ់មិញ ចង់ផង ខ្ពើមផង ខ្ញុំក៏អាចយល់ ស្រេចទៅហើយ ។

មិនដឹងជាចៃដន្យយ៉ាងម៉េច ខ្ញុំស្រាប់តែស្រមៃឃើញ អាវ៉ាវ៉ាន់កំពុងព្ទួយបូម លើប្រាណប្រពន្ធខ្ញុំ ខ្ទេចខ្ទីអស់នូវសេចក្តី បរិសុទ្ធ : ខ្ញុំស្រែកដង្ហោយ អូយយ៉ូយៗ! បានបីដង ក៏រត់ស្លុងទៅ មុខលែងគិតឃើញអ្វីៗទាំងអស់ ។ ខ្ញុំរត់យូរណាស់គ្មានដឹងហត់ គ្មានដឹងស្រគៀវជើងយ៉ាងម៉េចនោះទេៗ ។ លុះមកដល់ដើមស្រល់ មួយក្នុងភូមិជ្រោយធ្ម ក្បែរក្រសួងគយ និងរដ្ឋាករ ខ្ញុំក៏រត់ចុះច្រាំង គ្មានប្រណីតម្រង់ទៅទន្លេ ដើម្បីលោតចូលអោយដល់ស្រុកបិតុន្ទាត ឬស្រុកទ្រីវាសី[១] តែម្តង! ប៉ុន្តែនៅតែដប់ម៉ែត្រទៀតខ្ញុំនឹងទៅដល់

---

(១) ស្រុកបាតទន្លេ ឬស្រុកត្រីវាសុី

គង្ការ ជើងខ្ញុំក៏ជំពប់នឹងថ្មមួយ បណ្ដាលអោយខ្ញុំដួលស្រប៉ាប ។ ក្បាលខ្ញុំទង្គិចទៅគល់ឧសមួយដុំ បែកចេញឈាម ។ ខ្ញុំសន្លប់មិនដឹងខ្លួនអស់មួយសន្ទុះ ។ លុះខ្ញុំភ្ញារខ្លួនឡើងវិញ ខ្ញុំសើចក្អាកក្អាយសប្បាយជាពន្លឹក! សប្បាយមែនប្រុសៗ យើងបើកាលណាមានប្រពន្ធផិតដូច្នេះ "ទៅសម្លាប់ខ្លួនបានការអី ឱ! អាចង្កួតអញអើយ! ជីវិតគឺឥតន័យពិតប្រាកដហើយ ប៉ុន្តែជីវិតគឺជាល្បែងស្មោះ បើគេលួចប្រពន្ធយើងបាន គឺឧបមាដូចជាយើងចាក់កាតេជាមួយគេ ហើយមានអាតាជួងពីក្រោម ហើយស្រាប់តែគេចាក់ផាច់មកវិញមានអាត់ជួង ដូច្នោះយើងក៏ចាញ់គេស្មឿកមួយក្ដារទៅ ។ ប៉ុន្តែល្បែងទាល់តែមានចាញ់ខ្លះ ទើបសប្បាយ ទើបបានចង់លេងទៀត ។ ក្នុងជីវិតក៏ដូច្នេះដែរ ទាន់តែគេឱតប្រពន្ធយើងបានខ្លះ ទើបជីវិតយើងមានន័យ បើប្រពន្ធយើង វល់តែស្មោះត្រង់នឹងយើងពេក មិនដឹងជាស្រឡាញ់រកក្រមរំស្រែងអីទេ ។ អារឿងកុនឥណ្ឌាដែលនិយាយ ពីស្រីគ្រប់លក្ខណ៍ គឺជាអារឿងចំកួតតែម្ដង ឱ! អាពួកចំកួតសំពះក្ដិតគោញី..."

-ហាស់! ហាស់! ហាស់! (ខ្ញុំអស់សំណើច ហើយពោលតែម្នាក់ឯង) ជីវិតឥតន័យ! ជីវិតជាល្បែងថ្លុកល្ខោន! មែនទេមិត្ត?

នេះបានចាំ!! យើងរស់មែនទែន ក៏ដូចតែយើងរស់លេងៗ ។ យើងមិនទាំងដឹងខ្លួនផង ស្រាប់តែអាខ្លួនយើងវាជោរ ចេញភ្នែក ដុះត្រចៀក លេចច្រមុះ លាស់រោម និងអាកាយើងធ្លូញឆាញ គ្រប់មុខ មិនដឹងមកពីកាលណា! អារឿងស្មោកគ្រោកក៏ជាល្បែង អារឿងមានតម្លៃថ្លៃថ្នូរក៏ជាល្បែង ។ អ្វីៗក៏ជាល្បែងទាំងអស់! តាំងពីកើតមកឃើញព្រះអាទិត្យកាលណា មនុស្សយើងលេង រហូតទាល់ចូលរណ្តៅមរណៈទៅវិញ (ល្បែងយំ! សើច! ស្នេហា! សប្បាយ! កំប្លែង! កំសត់! ឈឺចាប់! អស់សង្ឃឹម! មួយចប់ តែម្តង...) ។ ក្នុងវ័យកម្លោះក្រមុំ យើងធ្វើឫកជាស្រឡាញ់គ្នា! ដោយអផ្សុកខ្លាំងពេក យើងធ្វើជារៀបការគ្នាជាប្តីប្រពន្ធ! ដល់ការរួចហើយ យើងនៅតែអផ្សុក ម្ល៉ោះហើយប្រពន្ធយើង លេងល្បែងរកសហាយ រួចខ្លួនយើងធ្វើឫកជោរកាច់រាង គិតរត់ ទៅរកលេងសម្លាប់ខ្លួន ដើម្បីសប្បាយដែរ...!

ខ្ញុំគិតឃើញដូច្នេះ ក៏សើចម្តងទៀតយ៉ាងខ្លាំងទាល់តែគាំង សរសៃ ទាល់តែហូរហៀរទឹកភ្នែក និងទឹកមាត់កក្លាក់ដូចឆ្កែឆ្កួត ។

ហាស់! ហាស់! ហាស់! ហាយ!

ខ្ញុំសើចយូរណាស់. រហូតដល់ម៉ោងប្រាំភ្លឺទៅហើយ ខ្ញុំនៅតែសើចដដែល ។ ខ្ញុំរសើបក្បាលពោះ អើយរសើប ។ សើចណាស់ រឹតតែរសើបណាស់! ចិន្តាមាសបងអើយ អូនរុញអ្វីខ្លះទៅឱ្យគេបួម...

-ហាស់!! ហាស់! ហាស់! ហាយ!ៗៗៗ ហួ! ហួស់! ហួស! ហួ... អ៊ូយ យូយៗៗ ហ៊ី! ហ៊ី! ហ៊ី!ៗៗៗ ។

ទីបំផុត ខ្ញុំសើចហើយតប់ផ្ដេញខ្លួនឯង រង្កើសណ្ដកអស់ពីរ-បី, ខ្ញុំគ្មានដឹងឈឺយ៉ាងម៉េចផងទេ ។

អាថៅកែខ្ញុំ ប្រហែលជាចេញឡាន ទៅស៊ីងត្រែងចោលខ្ញុំបាត់ទៅហើយ! ហ៊ឺ! អាឈឺមអើយ បើអ្ហែងដេញអញចោល មិនអោយធ្វើការក៏ដេញទៅចុះ ស្អែកអញទៅដេកឱបប្រពន្ធអញវិញ peut-être សប្បាយជាង... ។

-ហាស់! ហាស់! ហាស់! . . .

**ចប់**